ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ : ៣៥

ចុះថ្ងៃទី១០ខែវិច្ឆិកាឆ្នាំ១៩៩៩

<u>សាលដីកា</u>

លេខ : ២៨

ចុះថ្ងៃទី២០ខែកុម្ភៈឆ្នាំ២០០៣

កាលនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

ក្នុងបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី២០ ខែ កុម្ភៈ ឆ្នាំ ២០០៣ ដោយមានសមាសភាពដូចតទៅ :-

១- ឯកឧត្តម ឌិត មុន្នី ជាប្រធាន

២- លោក ស៊ុន នឹម ជាចៅក្រម

៣- លោក ឌីវ ខេង ជាចៅក្រម

៤- លោក សោមសិរីវឌ្ឍ ជាចៅក្រម

៥- លោក ឈឹម ស៊ីផល ជាចៅក្រម

៦- លោក ព្រាក់ គឹមសាន ជាចៅក្រម

៧- លោក យំ សួខៀន ជាចៅក្រម

៨- លោក ខឹម សារឿន ជាចៅក្រម

៩- លោក គង់ ភីរុន ជាចៅក្រមរបាយការណ៍

ក្រឡាបញ្ជី

លោក អ៊ូ សុផុន

តំណាងមហាអយ្យការ

លោក ហួន ចាន់ថា ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលើកទី ២ ពីសាលដីកាលេខ ២៧៦ ចុះថ្ងៃទី៣១ ខែ តុលា ឆ្នាំ ១៩៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៦៦ ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៦ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទអ្នកស្រី ង៉ែត សុជាតិ " ជាចុងបណ្តឹងសាទុក្ខ "អាយុ៣៧ឆ្នាំ ជាតិ ខ្មែរ មុខរបរ គ្រូបង្រៀន ទីលំនៅផ្ទះលេខ ១៩ ផ្លូវ ៣៣៦ ក្រុមទី ៥ សង្កាត់ ផ្សារដើមគរ ខណ្ឌ ទួលគោក ក្រុង ភ្នំពេញ ។

និង ចុងចម្លើយអ្នកស្រី ង៉ែត ខាត់ស្លូ " ជាម្ចាស់បណ្តឹងសាទុក្ខលើកទី២ " អាយុ ៦៨ ឆ្នាំ ទីលំនៅផ្ទះលេខ ១៩ ផ្លូវ ៣៣៦ ក្រុមទី ៥ សង្កាត់ ផ្សារដើមគរ ខណ្ឌ ទួលគោក ក្រុងភ្នំពេញ " ស្លាប់ " ផ្ទេរសិទ្ធិអោយលោក ញ៉ែម ចន្ទតារ៉ា " ។

<u>កម្មវត្ថុបណ្តឹង</u> : ប្តឹងទាមទាររកស្នាក់នៅ .

បានឃើញបណ្តឹងសាទុក្ខលើកទី២ លេខ ២៨០ ចុះថ្ងៃទី០៥.៨.១៩៩៩របស់ លោក ញ៉ាំ ចន្ទតារ៉ា ប្តឹងមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍លេខ២៧៦ ចុះថ្ងៃទី៣១.៥.១៩៩៩របស់ សាលាឧទ្ធរណ៍ ដើម្បីសេចក្តីសំរេចចាំងមួយ ។

បានឃើញសំនុំរឿងរដ្ឋប្បវេណីលេខ ៣៥០ ចុះថ្ងៃទី១០.១១.១៩៩៩ របស់ តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១៦.១២.៩១ របស់ឈ្មោះ កែវ សុផាតិ ដើមចោទ ប្តឹងទាមទារបែងចែកដីពាក់កណ្តាលរបស់ម្តាយនៃមេក្មេងជា ឈ្មោះ កែវ ទាន់ធួ ចុងចោទរួម ជាម្តាយ មិនបង្កើតខ្លួន បានយកដើមចោទនៅផ្ទះលេខ ២១មហាវិថី ក្រុម៥ សង្កាត់ផ្សារដើមគរ ។ នៅឆ្នាំ ១៩៨០ ម្តាយមិនបង្កើតខ្លួនបានយកកូនចិញ្ចឹមរបស់គាត់ឈ្មោះ ចាន់ ធី និង ទៅគាត់ពីទន្លេកាសាយ ៦_៧ ឆ្នាំ មកនៅ ជាមួយក្រោមការឧបត្ថម្ភរបស់ខ្លួន ។ ការរស់នៅជាមួយគ្នានេះរបេះរ៉ែងមានចំលាស់ខ្លួន ក៏សំរេចចិត្ត ចុះចេញពីផ្ទះមកសង់ផ្ទះនៅទីតាំងក្រោយវិញ ។ នៅឆ្នាំ ១៩៨៤_៨៥ ម្តាយមិនខ្លួន បានយកដីនោះឲ្យ តា ឈេង គ្រឹម ជំនីមាន នៅលើគ្រួសារក្រឡាញ់ ៥ពិន្ទុ រួចហើយខ្លួនទៅរកទៀតសំងាត់ ខ្លួនមាន ឈ្មោះ ក្មួយស្រីស្រួលការ ហើយខ្លួនក៏សុំតាមឈ្មោះក្មួយស្រីម្តាយមិនខ្លួនបិទព្រឹក ហើយគាត់ព្រមឲ្យ ដើមប្តឹងចាត់ខ្លួនទៀត ។ ខ្លួនឡើងផ្ទះនេះសំរាប់នៅខ្លួនឯង ហើយពេលនេះខ្លួនមានប្រាក់សល់សំរាប់ទិញ ផ្ទះនៅទទួលខ្លួនប្តឹង ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ០៦ " ក " ចុះថ្ងៃទី១៨.០១.៩៥របស់ តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :-

១- ទទួលពាក្យបណ្តឹងចុះថ្ងៃទី១៦.១២.១៩៩១ និង បណ្តឹងស៊ីវិលរបស់ដើមចោទ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែមិនមែនទោសលើអង្គសេចក្តីច្បាប់ ។

២- ប្រគល់ដី និង ផ្ទះលេខ ១៩ ផ្លូវលេខ ៣៣៦ ក្រុម ៥ សង្កាត់ ផ្សារដើមគរ ខណ្ឌ ទួលគោក ក្រុងភ្នំពេញ អោយទៅឈ្មោះនារី កែវ ទាន់ធួ តំណាងដោយឈ្មោះកែវកញ្ញារិទ្ធ គ្រប់គ្រងកាន់កាប់ប្រើប្រាស់ទាំងស្រុងតាំងពីថ្ងៃនេះតទៅ ។

៣- បង្គាប់អោយនារី កែវ សុផាតិ បង់ប្រាក់ប្រដាប់ក្តីពិពណ៌នាចុះបញ្ជីក្តី និងការទើង ចំនួន ១៨០០រៀល ចំនាត់ក្រមព្រាងបញ្ជីការពិតប្រាក់ ចំនួន ២០០រៀល ចំនាត់អ្នកប្រមូលនិងការរការ ចំនួន ៥០០០រៀល បូករួម ៧០០០រៀល ប្រាក់នេះកាត់យកពីប្រាក់ ៧០០០រៀល ដែលដើមចោទ បានបង់ទុកជាមុន ។

កាលបើសុំឧទ្ធរណ៍ហើយបង្គាប់អោយនារី កែវ សុផាតិ បង់ពន្ធមាតាប្រាក់ភាគរយ នៃតំលៃដីពាក់កណ្តាល តាមតំលៃផ្សារនេះ ដែលកំណត់ដោយការិយាល័យសុរិយោដីក្រុងភ្នំពេញ គឺ ស្មើ៣០០.១៣៥រៀល ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋចំនួន ៨០ភាគរយ គឺស្មើ ២៤០.១០៨រៀល និង

បានផ្សារភ្ជាប់ក្រដាសពន្ធតម្លៃចំពោះប្រទេស ចំនួន ២០ភាគរយ គឺស្មើ៦០.០២៣រៀល តាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ។

៤_ សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្តីសំរេចបើកផ្លូវឧទ្ធរណ៍ រយៈពេល ២ខែ គិតចាប់តាំងពីថ្ងៃនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ ទៅ សំសុខារី ចុះថ្ងៃទី១៨.០១.៩៥ ម្តងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ០៦ក ចុះថ្ងៃទី១៨.០១.៩៥របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចចាំងខ្លួន ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៤១១ ចុះថ្ងៃទី២៨.០៤.៩៥ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :-

១_ ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៨.០១.៩៥របស់ឈ្មោះ ទៅសំសុខារី ជាអ្នកតំណាងអោយឈ្មោះ វ៉ាន់ សុផាត " រស៊ីមចាន់ " ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ដែលមិនហួសពេលវេលាដែលកំណត់ដោយនីតិច្បាប់ ។

២_ តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ០៦ ចុះថ្ងៃទី១៨.០១.១៩៩៥ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការពេញចាំងខ្លួន ។

៣_ សំរេចរឹបអូសប្រាក់ប្រដាប់ក្តី ១៣.០០០រៀល ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និង ពន្ធថ្លឹង ២៥៥០រៀល ស្លាកក្រដាសពន្ធការពារប្រាក់ ៤៥០រៀល ចំណាយលើអ្នកប្រគល់ដីកាកោះ ៥០០០រៀល និង អាហារតុលាការ៥០០០រៀល សរុប ១៣.០០០រៀល ។

៤_ សាលដីកានេះសំរេច និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី សំរេចបើកផ្លូវប្តឹងសាទុក្ខកំណត់រយៈពេល ២ខែគិតចាប់ពីថ្ងៃប្រកាសសាលដីកានេះតទៅ ។

បានឃើញបណ្តឹងសាទុក្ខលេខ ២៤៨ ចុះថ្ងៃទី០២.១០.៩៥របស់អ្នកស្រីវ៉ាន់សុផាត ម្តងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៤១១ ចុះថ្ងៃទី២៨.៤.៩៥របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចចាំងខ្លួន ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៣៧ ចុះថ្ងៃទី៣០.០៥.១៩៩៦របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :-

១_ ទទួលបណ្តឹងសាទុក្ខលេខ ២៤៨ ចុះថ្ងៃទី០២.១០.៩៥របស់នាងវ៉ាន់សុផាត ទុកត្រឹមត្រូវតាមទំរង់ និង នីតិច្បាប់ ។

២_ ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៤១១ ចុះថ្ងៃទី២៨.៤.៩៥ របស់សាលាឧទ្ធរណ៍ចាំងខ្លួន ។

៣_ បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៣១៦ ចុះថ្ងៃទី ២០.១២.១៩៩៥របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះសាជាថ្មីទៀតវិញ ។

--- ៤ --

៤- រីឯប្រាក់ប្រដាប់ក្តីដែលនាង រ៉េត សុផាតិ ត្រូវបង់រួចហើយ ចំនួន ១៩.០០០រៀល គឺ :-

- ពន្ធចុះបញ្ជីក្តី និង ពន្ធតែម ចំនួន ៤.០០០រៀល បូករួមប្រាក់ប្រូវិសិក ចំនួន ៨០០រៀល សំរាប់ការចំណាយក្រដាសបញ្ជីការពិតប្រាកដ ។

- ចំណាយក្នុងកិច្ចប្រតិបត្តិការ ចំនួន ១៥.០០០រៀល

សរុប ១៩.០០០រៀល ដើម្បីឲ្យជូនចោទប្រកាន់ រ៉េត ចាន់ធូ សងប្រាក់ ចំនួន ១៩.០០០រៀល ទៅអោយនាង រ៉េត សុផាតិ វិញ ។

៥- សាលដីកានេះប្រកាសនាពេលសវនាការសាធារណៈ នៅថ្ងៃទី៣០ ខែ ឧសភា ឆ្នាំ ១៩៩៦ ។

តាមសាលដីកាសង្ខេបដំណើររឿងលេខ២៣៦ ចុះថ្ងៃទី៣១.០៥.១៩៩៩របស់ សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :-

១- ទទួលពាក្យប្តឹងឧទ្ធរណ៍តាមសង្ខេបដំណើររឿងលេខ៦៦ ចុះថ្ងៃទី០៧.៨.៩៦តាម ជំទាស់សាលដីកាតុលាការដំបូងលេខ ១៣៧ ចុះថ្ងៃទី៣០.០៥.៩៦ ។

២- បដិសេធសាលក្រមលេខ ០៦ "ក" ចុះថ្ងៃទី១៨.០១.៩៥ របស់ តុលាការក្រុងភ្នំពេញ ទោះសាមញ្ញារបស់ ។

៣- សំរេចរំលងរ៉េតក្តី និង ដីកាលេខ ១៩ ចុះនៅក្រុង ៥ ផ្លូវលេខ៣៣៦ សង្កាត់ផ្សារដើមគរ ខាងកើតចំណែកជើង ជូនចំណែកប្រគល់អោយឈ្មោះ រ៉េត សុផាតិ និង ជួយ ចំណែកខាងត្បូងប្រគល់អោយឈ្មោះ ញឹម ចន្ទតារ៉ា តំណាងអោយឈ្មោះ រ៉េត ចាន់ធូ ។

៤- សាលដីកានេះមិនស្ថិតនៅ និង ប្រកាសជាសាធារណៈចំពោះមុខ ឈ្មោះ រ៉េត សុផាតិ កំបាំងមុខឈ្មោះ ញឹម ចន្ទតារ៉ា តំណាងអោយឈ្មោះ រ៉េត ចាន់ធូ ដើម្បីតវ៉ាក្នុងកំណត់ច្បាប់ ។

តាមពាក្យបណ្តឹងសាទុក្ខលេខ ២៨០ ចុះថ្ងៃទី០៥.៨.៩៩របស់ឈ្មោះញឹម ចន្ទតារ៉ា ប្តឹងមិនសុខចិត្តនឹងសាលដីកាសង្ខេបដំណើររឿងលេខ២៣៦ ចុះថ្ងៃទី៣១.០៥.៩៩ របស់សាលាឧទ្ធរណ៍ ស៊ើ សេចក្តីសំរេចទាំងមូល ។

តាមសាលដីកាសេចក្តីលេខ ២៤១ ចុះថ្ងៃទី៣០.១១.២០០០ របស់ តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :-

១- ចាត់សេចក្តីអោយទៅក្រុមប្រឹក្សាតុលាការកំពូល ចុះពិនិត្យផ្ទាល់ ទីកន្លែងជំលោះ ។

២- សាលដីកានេះប្រកាសនាពេលសវនាការសាធារណៈនៅថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ២០០០ ។

បានឃើញបណ្ដឹងសាទុក្ខលើកទី២ លេខ ២៤០ ចុះថ្ងៃទី០៥.៨.១៩៩៩ របស់លោក ញ៉ិម ឧត្តមារ៉ា ប្ដឹងមិនសុខចិត្តនឹងសាលដីកាសម្រេចលេខ ២៧៦ ចុះថ្ងៃទី៣១.៥.៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសំរេចទាំងមូល ។

អ្នកស្រី កែវ ទាត់ភួ ជាម្ចាស់បណ្ដឹងសាទុក្ខលើកទី២ បានទទួលលិខិតបង្គាប់ អោយផ្ញើសារណា ចុះថ្ងៃទី២៧.១២.៩៩ របស់តុលាការកំពូលរួចហើយ ប៉ុន្តែអ្នកស្រី ពុំបានផ្ញើសារណាជូនតុលាការកំពូល វិញទេ ។

បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា: រឿងនេះជាវិវាទ ទាមទារដីកសម្លាក់ទៅ ។

សូមក្រុមប្រឹក្សាជំនុំជម្រះសំរេច ។

បានស្ដាប់ចម្លើយរបស់លោក ញ៉ិម ឧត្តមារ៉ា តំណាងអោយចុងចម្លើយនាពេលសវនាការបានលើកឡើងថា: ដីខាងលើនេះស្រាវជ្រាវឃើញថានេះពីមុនជាដីក្នុងរបស់ក្រសួងគមនាគមន៍ ពេលនោះខ្ញុំនៅធ្វើការនៅក្រសួង ខាងក្រោមបានឡើងក្រសួងគមនាគមន៍ ម្ដាយក្មេកខ្ញុំ ក៏បានសុំដីនេះពីក្រសួងគមនាគមន៍ជាក់ទៅ ពេលសុំបានហើយរដ្ឋអំណាច ក៏ប្រគល់ដីលេខ ១៩នេះមកអោយម្ដាយក្មេកខ្ញុំ នៅតាមលិខិតជាងរបស់លោកជុំ ម៉ារ៉េត ទៀតផង ។

បានស្ដាប់ចម្លើយរបស់អ្នកស្រី កែវ សុផាធិ ជាដើមចោទនាពេលសវនាការបានលើកឡើងថា: ពាក្យនេះជាពាក្យមួយបង្គាប់ទាំងស្រុងដីនេះជាដីចំណេះទៅខាងកើតផ្ទះខ្លួន សុំប្រគល់មកល្អាក់ទៅនៅជាប់ផ្ទះ និង បារាំង ។ ខ្លួន សុំមកនៅឆ្នាំ១៩៨១ដល់ឆ្នាំ៨៤ ទើបខ្លួន ចុះមកនៅ ម្ដាយខ្ញុំ ចុះមកនៅជាមួយខ្លួននៅតាមតែនៅមិនចុះសំរុងជាមួយគ្នា មិនមែនខ្លួន សុំតាក់នៅទេ ។

- ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់ចម្លើយដោះសាររបស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ២៤០ ចុះថ្ងៃទី០៥.៨.១៩៩៩ របស់ ញ៉ិម ឧត្តមារ៉ា ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្ដីពីការបង្កើតតំណាង និង សកម្មភាពរបស់សាលាជំរះក្ដី និង តាមមាត្រា២២៦ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌដែលមានអនុភាពអនុវត្តក្នុងរឿងរដ្ឋប្បវេណីផងដែរ ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចប្រគល់ដីចំណាស់ពាក់កណ្តាលទៅអ្នកស្រី កែវ សុផាតិ ដោយសំអាងហេតុថាដីចំណាស់លោក សួន សាន់ធារី អនុប្រធានឃុំ និង លោក សុខ សារ៉ូ ប្រធាន ឃុំ បានប្រគល់អោយអ្នកស្រី កែវ សុផាតិ ហើយពុំមានសក្ខីភាពណាមួយបញ្ជាក់ថា លោក ឈុំ ចាំរើត បានប្រគល់អោយចុងចម្លើយនោះជាការពុំត្រឹមត្រូវទេ ពីព្រោះថាដើមចោទ ក៏ពុំមានឯកសារប្រគល់ដីនេះពីលោក សួន សាន់ធារី និងលោក សុខ សារ៉ូ ដែរ ។ បញ្ជាក់ទៀតតាមកំណត់ហេតុយកចម្លើយលោក សុខ សារ៉ូ ចុះថ្ងៃទី៣១.០១.៩៥ លោកបានឆ្លើយថា អ្នកស្រី កែវ ចាន់ធួ ជាអ្នកទៅសុំដីចំណាស់នេះពីលោក ដោយអ្នកស្រីកែវសុផាតិ ពុំបានទៅជាមួយទេ ហើយនៅពេលសវនាការនេះដើមចោទ បានអះអាងថាអ្នកស្រី ពុំបានឃើញលិខិតដែលលោក ឈុំ ចាំរើត បានប្រគល់ដីនេះអោយចុងចម្លើយទេ អ្នកស្រីគ្រាន់តែបានដឹងថា លោក ឈុំ ចាំរើត បានប្រគល់ដីនេះអោយចុងចម្លើយ ចម្លើយនេះស្ថិតនៅក្នុងកំណត់ហេតុ ចុះថ្ងៃទី០២.៧.៩២ ទំព័រ ៣ ដែលដើមចោទឆ្លើយថា ដីចំណាស់នេះក្រសួងបានប្រគល់អោយឈ្មោះ កែវ ចាន់ធួ ហើយអ្នកស្រី បានមកនៅលើដីនេះឆ្នាំ១៩៨៤ ។

- យល់ឃើញថា ដើមចោទបានអះអាងថា ដីចំណាស់អ្នកស្រីបានសុំពីប្រធាន និង អនុប្រធានឃុំហើយអ្នកស្រី ជាអ្នកសង់ផ្ទះ រីឯចុងចម្លើយក៏អះអាងដែរថា ដីចំណាស់នេះលោក ឈុំ ចាំរើត ជាអតីតអាជ្ញាធរក្រសួងពេទ្យជាអ្នកប្រគល់អោយហើយខ្លួនជាអ្នកសង់ផ្ទះដែរ ប៉ុន្តែភាគី ពុំមានលិខិតប្រគល់ដី និង ភស្តុតាងគ្រប់គ្រាន់ស្តីពីការសង់ផ្ទះនេះទេ ដូចនេះតុលាការក៏គួរ គប្បីពិចារណាលើកិរិយាកាន់កាប់ជាក់ស្តែង ដើម្បីសំរេចអំពីសិទ្ធិលើដីចំណាស់នេះ ។

- យល់ឃើញថា ចុងចម្លើយឈ្មោះ កែវ ចាន់ធួ និង ទៅពីរនាក់ពិតជាបាន រស់នៅលើដី និង ផ្ទះលេខ ៣៩ ស្ថិតនៅក្រុមទី ៥ ផ្លូវ ៣៣៦ សង្កាត់ផ្សារដើមថ្កូវ ប្រាកដមែន ដោយមានបញ្ជីគ្រួសារជាសំគាល់ ។ ដោយឡែកអ្នកស្រី កែវ សុផាតិ ដែលបានអះអាងថា បានសុំ ដីទួលនេះលេខ១៩ ផ្លូវ ៣៣៩ និង បានសង់ផ្ទះជាមួយដែលនៅដែរនោះពុំមានឈ្មោះក្នុងបញ្ជីគ្រួសារ លើដី និង ផ្ទះចំណាស់នេះទេ ប៉ុន្តែបែរជាមានឈ្មោះក្នុងបញ្ជីគ្រួសារមួយទៀតជាមួយគ្រួសារក្នុង បញ្ជីជាស់នៅលើផ្ទះលេខ ១១Z បន្ទប់លេខ ២២ ផ្លូវ ៣៣៦ នៅពីក្រោយផ្ទះ និង ដីចំណាស់នេះទៅវិញ ដែលអ្នកស្រី បានរស់នៅរហូតដល់សព្វថ្ងៃ ។ ប៉ុន្តែដោយដីពាក់កណ្តាល ត្រូវបានចុងចម្លើយ លក់អោយគេរួចហើយ នៅសល់ពាក់កណ្តាលទៀតដែលជាទីកំព្រារបស់ចុងចម្លើយ បានរស់នៅតាំងពីឆ្នាំ១៩៨០ ឬ ១៩៨១ រហូតដល់បច្ចុប្បន្ននេះគប្បីប្រគល់អោយនៅជារបស់ ចុងចម្លើយ កាន់កាប់គ្រប់គ្រងតទៅ ។

- យល់ឃើញថា សាលដីការឧទ្ធរណ៍លេខ ២៧៦ ចុះថ្ងៃទី៣១ ខែ តុលា ឆ្នាំ ១៩៩៤ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះខានការពិនិត្យទាំងស្រុង ទាំងគតិ ច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខក្តី

១_ ទទួលបណ្តឹងសាទុក្ខលេខ ២៨០ ចុះថ្ងៃទី០៥ ខែ សីហា ឆ្នាំ ១៩៩៩ របស់ឈ្មោះ ញ៉ឹម ចន្ថារ៉ា ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២_ ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ២៧៦ ចុះថ្ងៃទី៣១ ខែ តុលា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣_ សំរេចប្រគល់ដី និង ផ្ទះទំនាស់តាមតំរូវប្លង់បង្ហាញទីតាំងដីទំនាស់ ចុះថ្ងៃទី២២.០២.២០០២របស់ចៅក្រមតុលាការកំពូល អោយឈ្មោះ ញ៉ឹម ចន្ថារ៉ា ជាតំណាងដែលសិទ្ធិវន្ត របស់មេពអ្នកស្រី ង៉ែត ខាន់ម្ម កាន់កាប់គ្រប់គ្រងតទៅ ។

៤_ រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រៀលដែលចុងចម្លើយ បានបង់ពី :

\- ពន្ធចុះបញ្ជីក្តី និង ពន្ធតែម ចំនួន ៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀលសំរាប់ផ្ទេរទៅក្រសួងបញ្ជីកាន់ដិបប្រាក់ ។

\- ចំណាយលើការប្រគល់ដីការកោះចំនួន១៥.០០០រៀល សរុប១៩០០០រៀល ហើយត្រូវអោយដើមចោទ សងប្រាក់ ១៩.០០០រៀលនេះទៅចុងចម្លើយ វិញ ។

៥_ សាលដីការនេះជំនុំជំរះដោយនីតិវិធីសាធារណៈនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ ២០០៣ និង ប្រកាសនៅថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៣ ។